អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១៣

# សេចក្តីប្រកាសព័ត៌មាន
# សវនាការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សា
# ដេញដោលលើសំណុំរឿង ០០២/០១ បានបិទបញ្ចប់នៅថ្ងៃនេះ

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានបញ្ចប់សវនាការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង ០០២/០១ ដែលមានរយៈពេល ១០ ថ្ងៃ ពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣។ នាពេលនេះ អង្គជំនុំជម្រះត្រូវធ្វើការពិភាក្សាដើម្បីសម្រេច ហើយរំពឹងថា សាលក្រមលើសំណុំរឿងនេះនឹងត្រូវចេញនៅក្នុងអំឡុងពេលឆមាសទីមួយឆ្នាំ ២០១៤។

សវនាការលើផ្នែកអង្គសេចក្តីនៃការជំនុំជម្រះនេះ បានចាប់ផ្តើមដំណើរការ ដោយមានការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់នៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ហើយសវនាការពិនិត្យភស្តុតាងបានបញ្ចប់នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣។ សវនាការជំនុំជម្រះ រួមទាំងការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល មានរយៈពេលសរុបចំនួន ២២២ ថ្ងៃ។

បុគ្គលចំនួន ៩២ រូប បានមកផ្តល់ភស្តុតាងក្នុងអំឡុងពេលសវនាការជំនុំជម្រះក្តីនេះ ដែលរួមមាន សាក្សីជំនាញចំនួន ៣ រូប សាក្សីបញ្ជាក់អង្គហេតុចំនួន ៥៣ រូប សាក្សីបញ្ជាក់ពីអត្តចរិតជនជាប់ចោទចំនួន ៥ រូប និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣១ រូប។ លើសពីនេះទៀត គ្រូពេទ្យព្យាបាលជនជាប់ចោទចំនួន ២ រូប និងអ្នកជំនាញផ្នែកវេជ្ជសាស្ត្រចំនួន ២ រូប ក៏បានមកផ្តល់សក្ខីកម្មអំពីស្ថានភាពសុខភាពរបស់ជនជាប់ចោទដែរ។

ការជំនុំជម្រះត្រូវបានសាធារណជនមានការចាប់អារម្មណ៍យ៉ាងខ្លាំងដែលពុំធ្លាប់មានពីមុនមក ដោយមានអ្នកចូលរួមចំនួន ១០៣ ២៧៤ នាក់ បានមកតាមដានសវនាការចំនួន ២២២ ថ្ងៃនេះ ដោយផ្ទាល់។

ជនជាប់ចោទដែលត្រូវជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ មាន នួន ជា ដែលជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និង ខៀវ សំផន ជាប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ។ បទចោទនៅក្នុងសំណុំរឿង ០០២/០១ ផ្តោតទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីក្រុងភ្នំពេញនៅ ខែ មេសា ឆ្នាំ ១៩៧៥ និងការផ្លាស់ទីលំនៅប្រជាជនចេញពីតំបន់ផ្សេងៗនៅពេលក្រោយមកទៀត (ដំណាក់កាលទី១ និងទី២)

និងការសម្លាប់ទាហានរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃក្នុងខេត្តពោធិ៍សាត់។ អង្គជំនុំជម្រះសាលាដំបូងក៏បានធ្វើសវនាការពិនិត្យលើភស្តុតាងស្តីពីសាវតារប្រវត្តិសាស្ត្រ និងការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់ជនជាប់ចោទនៅក្នុងរដ្ឋាភិបាល រួមទាំង ភស្តុតាងស្តីពីរចនាសម្ព័ន្ធរដ្ឋបាល និងទំនាក់ទំនងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក **ឡាស អលសិន**
មន្ត្រីទំនាក់ទំនងច្បាប់
ទូរស័ព្ទដៃ: +៨៥៥(០)១២ ៤៨៨ ០២៣
ទូរស័ព្ទ: +៨៥៥(០)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិច: olsenl@un.org

លោក **នេត្រ ភក្ត្រា**
មន្ត្រីអ្នកនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥(០)១២ ៤៨៨ ១៥៦
ទូរស័ព្ទ: +៨៥៥(០)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិច: neth.pheaktra@eccc.gov.kh